**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៤៨/៣ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ 20១២

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**<u>សូមគោរពជូន</u>**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់**

**<u>កម្មវត្ថុ</u>** ៖ សំណើសុំលុបគោលការណ៍ និងកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ចចំនួន ១២ ក្រុមហ៊ុន : ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត ស្រុកកែវសីមា និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ស្រុកអណ្តូងមាស និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ស្រុកសន្ទុក ខេត្តកំពង់ធំ និងស្រុកក្រចេះ ស្រុកសំបូរ និងស្រុកស្នួល ខេត្តក្រចេះ ។

**<u>យោង</u>** ៖
- កិច្ចសន្យាចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រុមហ៊ុន វើលដ៍ ត្រីស្តារ អ៊ិនធើធេនមេន (ខេមបូឌា) (WORLD TRISTAR ENTERTAINMENT (CAMBODIA) Co., Ltd)
- កិច្ចសន្យាចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៥ រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រុមហ៊ុន ហ្វឺស បាយអូ-ធេក អេគ្រីខលឈើរេល (ខេមបូឌា) (FIRST BIO-TECH AGRICULTURAL (CAMBODIA) Co., Ltd)
- កិច្ចសន្យាចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៨ រវាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រុមហ៊ុន អាគ្រោ ហ្វរ៉េស្ទ្រី រីស៊ើច (AGRO FORESTRY RESEARCH Co., Ltd)
- កិច្ចសន្យាចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រុមហ៊ុន ហេង អភិវឌ្ឍន៍ (HENG DEVELOPMENT Co., Ltd)
- កិច្ចសន្យាចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រុមហ៊ុន ហេង ហ៊ាប អ៊ិនវេសមេន (HENG HEAP INVESTMENT Co., Ltd)
- កិច្ចសន្យាចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ រវាងអនុគណៈកម្មការវិនិយោគខេត្តកំពង់ធំ និងក្រុមហ៊ុន ហេង មាន អ៊ិនវេសមេន (HENG MEAN INVESTMENT Co., Ltd)



អគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (០២៣) ២១៦ ១២៨ / ២១៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០

- កិច្ចសន្យាចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៨ រវាងអនុគណៈកម្មការវិនិយោគខេត្តក្រចេះ និងក្រុមហ៊ុន ក្រចេះ ស៊ីធី ផៅវើរ លីមីធីត (KRATIE CITY POWER Ltd)
- កិច្ចសន្យាចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៨ រវាងអនុគណៈកម្មការវិនិយោគខេត្តក្រចេះ និងក្រុមហ៊ុន GOLD MENTHOL II Co., Ltd
- កិច្ចសន្យាចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៨ រវាងអនុគណៈកម្មការវិនិយោគខេត្តក្រចេះ និងក្រុមហ៊ុន MEKONG S.C DEVELOPMENT Co., Ltd
- កិច្ចសន្យាចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨ រវាងអនុគណៈកម្មការវិនិយោគខេត្តក្រចេះ និងក្រុមហ៊ុន ភី អេស ពាយ ខូអិលធីឌី
- កិច្ចសន្យាចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៨ រវាងអនុគណៈកម្មការវិនិយោគខេត្តក្រចេះ និងក្រុមហ៊ុន ស៊ីល ឌីវេឡុបមេន (SEAL DEVELOPMENT Co., Ltd)
- សេចក្ដីជូនដំណឹងលេខ ៦៨២ សជណ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

**ជូនភ្ជាប់៖** របាយការណ៍ស្ដីពី លទ្ធផលចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទូទាំងប្រទេស ពីថ្ងៃទី ១០-២០ ខែ មករា ឆ្នាំ ២០១១។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ យោង និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបថា : ក្នុងគោលបំណងជំរុញការវិនិយោគសម្បទានដីសេដ្ឋកិច្ចឱ្យទទួលបានផ្លែផ្កាស្របតាមកិច្ចសន្យា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានបង្កើតយន្តការត្រួតពិនិត្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចាប់ពីថ្នាក់កណ្ដាលរហូតដល់ថ្នាក់មូលដ្ឋាន ហើយនឹងបានកំណត់ឲ្យក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចទាំងអស់រាយការណ៍មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជារៀងរាល់ ០២ ខែម្ដង។ បន្ថែមលើនេះរៀងរាល់ឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានបង្កើតក្រុមការងារចម្រុះ ដែលមានសមាសភាពពីលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ចមន្ត្រីជំនាញ និងថ្នាក់ដឹកនាំនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចុះពិនិត្យផ្ទៀងផ្ទាត់ និងវាយតម្លៃសកម្មភាពវិនិយោគ របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទូទាំងប្រទេស។ យ៉ាងណាមិញ សម្រាប់ការងារឆ្នាំ ២០១០នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានចាត់ក្រុមការងារចម្រុះចំនួន ០៧ ចុះពិនិត្យផ្ទៀងផ្ទាត់និងវាយតម្លៃសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៦ ខេត្ត ដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទកន្លងមក។ ចំពោះមុខនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានប្រជុំវាយតម្លៃ វិនិច្ឆ័យបន្ថែមទៅលើរបាយការណ៍នៃការចុះពិនិត្យរបស់ក្រុមការងារ ហើយដែលលទ្ធផលទទួលបាន គឺមានក្រុមហ៊ុនចំនួន ៥១ បានអនុវត្តតាមកិច្ចសន្យា និងផែនការមេបានត្រឹមត្រូវ ក្រុមហ៊ុនចំនួន

៧៥ នឹងត្រូវបានណែនាំកែលម្អ ឬព្រមាន រីឯក្រុមហ៊ុនចំនួន ១៦ មានការអសកម្ម ពុំបានយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារនៃកិច្ចសន្យា និងផែនការមេទៀយ ដូចជាការអនុវត្តមានភាពយឺតយ៉ាវខ្លាំង អូសបន្លាយពេលវេលា អាក់ខានសកម្មភាពផលិតកម្មលើសពីការកំណត់ក្នុងកិច្ចសន្យា ដោយមិនបញ្ជាក់ ឬគ្មានមូលហេតុសមស្រប បណ្តែតបណ្តោយឲ្យមានសកម្មភាពកាប់ឈើល្មើសច្បាប់ និងការកាប់ទន្ទ្រានដីរដ្ឋក្នុងដែនសម្បទានដីជាដើម។ ក្រុមហ៊ុនទាំង ១២ មានដូចខាងក្រោម ៖

១. ក្រុមហ៊ុន វើលដ៍ ត្រីស្តារ អ៊ិនធើធេនមេន (ខេមបូឌា) (WORLD TRISTAR ENTERTAINMENT (CAMBODIA) Co., Ltd) លើផ្ទៃដីចំនួន ៩.៨០០ ហិកតា ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។

២. ក្រុមហ៊ុន ហ្វឺស បាយអូ-ថេក អេហ្គ្រីខលឈើរល (ខេមបូឌា) ) (FIRST BIO-TECH AGRICULTURAL (CAMBODIA) Co., Ltd) លើផ្ទៃដីចំនួន ១០.០០០ ហិកតា ស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។

៣. ក្រុមហ៊ុន អាគ្រោ ហ្វរ៉េស្ទ្រី រីស៊ើច (AGRO FORESTRY RESEARCH Co., Ltd) លើផ្ទៃដីចំនួន ៧.០០០ ហិកតា ស្ថិតនៅក្នុងឃុំចុងផ្លាស់ ស្រុកកែវសីមា និងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី។

៤. ក្រុមហ៊ុន ហេង ឌេវេឡុបមេន (HENG DEVELOPMENT Co., Ltd) លើផ្ទៃដីចំនួន ៨.៦៥៨ ហិកតា ស្ថិតនៅក្នុងស្រុកអណ្តូងមាស ខេត្តរតនគីរី។

៥. ក្រុមហ៊ុន ហេង ហ៊ាប អ៊ិនវេសមេន (HENG HEAP INVESTMENT Co., Ltd) លើផ្ទៃដីចំនួន ៧.០០០ ហិកតា ស្ថិតនៅក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគីរី។

៦. ក្រុមហ៊ុន ហេង មាន អ៊ិនវេសមេន (HENG MEAN INVESTMENT CO., LTD) លើផ្ទៃដីចំនួន ៩១៧ ហិកតា ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។

✓ ៧. ក្រុមហ៊ុន ក្រចេះ ស៊ីធី ផៅវ័រ អិលធីឌី (KRATIE CITY POWER Ltd) លើផ្ទៃដីចំនួន ៨០០ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ។

✓ ៨. ក្រុមហ៊ុន GOLD MENTHOL II Co., Ltd លើផ្ទៃដីចំនួន ៨២៤ ហិកតា ស្ថិតនៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ។

✓ ៩. ក្រុមហ៊ុន MEKONG S.C DEVELOPMENT Co., Ltd លើផ្ទៃដីចំនួន ៨៣៨ ហិកតា ស្ថិតនៅក្នុងស្រុកក្រចេះ ខេត្តក្រចេះ។

✓ ១០. ក្រុមហ៊ុន ភី អេស វាយ ខូអិលធីឌី លើផ្ទៃដីចំនួន ៩៥០ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ។

✓ ១១.ក្រុមហ៊ុន ស៊ីល ឌីវេឡុបមេន (SEAL DEVELOPMENT Co., Ltd) លើផ្ទៃដីចំនួន ៩៥០ ហិកតា ស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ។

✓ ១២.ក្រុមហ៊ុន TTY Cooperation Co., Ltd លើផ្ទៃដីចំនួន ៩២៨ ហិកតា ស្ថិតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។

ដូចនេះ ដើម្បីគ្រប់គ្រងដីរដ្ឋឱ្យបានគង់វង្ស និងជៀសវាងការទុកដីចោលទំនេរមិនធ្វើវិនិយោគ ជាហេតុនាំឱ្យមានការចូលកាប់ពនដីព្រៃ ចាប់យកដីរដ្ឋទៅលក់ឱ្យឯកជនបែបអនាធិបតេយ្យ ហើយនិងការរាំងស្ទះ ឬប៉ះពាល់ដល់ដំណើរការវិនិយោគសម្បទានដីសេដ្ឋកិច្ច ជាទូទៅនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ យល់ថា គួរលុបគោលការណ៍ និងកិច្ចសន្យាវិនិយោគសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនទាំង ១២ ខាងលើ ហើយដកហូតមកវិញនូវដីសម្បទានសេដ្ឋកិច្ចនេះ ដើម្បីទុកជាសម្បត្តិរដ្ឋវិញ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។